# កម្មវិធីផ្ញើសារតាមទូរស័ព្ទ

## ១.គោលបំណង

កម្មវិធីនេះបង្រៀនជូនដល់បណ្តាញខេត្តក្រុង និងបុគ្គលិកស្នាក់ការកណ្តាលឱ្យចេះប្រើប្រាស់ពី របៀបបញ្ជូនព័ត៌មាន ដូចជាប័ណ្ណពិន្ទុប្រជាពលរដ្ឋ និងរបាយការណ៍ថ្ងៃរាប់សន្លឹកឆ្នោត ភាពមិនប្រក្រតី នៅមុនពេល និងពេលបោះឆ្នោត សំណួរស្ទង់មតិ ។ល។

## ២.របៀបប្រើប្រាស់ទូរស័ព្ទ

ការប្រើប្រាស់សារលើទូរស័ព្ទ (SMS) វាប្រែប្រួលតាមប្រភេទនៃទូរស័ព្ទ ក៏ប៉ុន្តែប្រភេទខ្លះវាមានកន្លែងបញ្ជារប្រហាក់ប្រហែលគ្នា ចូរមើលរូបភាពខាងក្រោមៈ



រូបភាពទាំងអស់នេះ មានទ្រង់ទ្រាយក្នុងការប្រើប្រាស់ប្រហាក់ប្រហែលគ្នា សូមមើលការណែនាំ ដូចខាងក្រោមៈ




**<u>ចំណាំ:</u>** នៅក្នុងកម្មវិធីផ្ញើសារ សូមមើលលើអេក្រង់ទូរស័ព្ទ នៅពេលដែលអ្នកចុចលើ

- អ្វីទៅជាគ្រាប់ចុច **បញ្ជារមីនុយ**? ។ វាជាគ្រាប់សំរាប់បើកកម្មវិធី
- អ្វីទៅជាគ្រាប់ចុច **បញ្ជារយល់ព្រម**?។ វាជាគ្រាប់បញ្ជារសំរាប់ទទួលយកនូវកិច្ចការដែលយើងបានជ្រើសរើស
- អ្វីទៅជាគ្រាប់ចុច **បញ្ជារឡើង ចុះ**?។ វាជាគ្រាប់ចុចសំរាប់រំកិលការជ្រើសរើសពីកម្មវិធីមួយទៅកម្មវិធីមួយទៀត
- អ្វីទៅជាគ្រាប់ចុច **បញ្ជារថយក្រោយ ឬលុប**?។ ជាកម្មវិធីប្តូរផ្ទាំងកិច្ចការ ឬលុបអក្សរពេលអ្នកសរសេរ

## ២.១.ជំហានទី១ ការជ្រើសរើសកម្មវិធីលើទូរស័ព្ទសំរាប់សរសេរសារ

ទី១- ចុចលើរូបសញ្ញាបញ្ជារមីនុយ (Menu) 




នៅពេលនោះវា និងលេចចេញនូវកម្មវិធីមួយចំនួន ដូចរូបបង្ហាញនេះ

ទី២- ចុចលើ**សញ្ញារំកិល**ណាមួយ ដើម្បីជ្រើសរើសកម្មវិធីដែលត្រូវការ (ក្នុងករណីនេះជ្រើសរើស**កម្មវិធី ផ្ញើសារ** ឬសញ្ញា**ស្រោមសំបុត្រ**ដូចរូបខាងក្រោម)។




ទី៣- ពេលជ្រើសរួច ចុចលើ រូប**សញ្ញាបញ្ជារយល់ព្រម** 

**ចំណាំ:** ដើម្បីបើកកម្មវិធីណាមួយ ជាដំបូងអ្នកត្រូវតែចុចលើ រូប**សញ្ញាបញ្ជារមីនុយ** បន្ទាប់មកចុចលើរូប **សញ្ញារំកិល** ឡើងចុះ (រូបសញ្ញាមានព្រួញឡើងចុះ) ខណ:នោះចូរអ្នកជ្រើសរើសកម្មវិធីដែលអ្នកត្រូវការប្រើ។

## ២.២.ជំហានទី២ ការសរសេរសារ (ឬសរសេរអក្សរ) លើកម្មវិធី

ទី១. នៅពេលជ្រើសរើសកម្មវិធីរួច ចុចលើ **សញ្ញាបញ្ជារយល់ព្រម**

ទី២. ជ្រើសរើសពាក្យ "SMS **ឬពាក្យថា** Messaging តាមប្រភេទទូរស័ព្ទ" បន្ទាប់មកចុចលើ **សញ្ញាបញ្ជារយល់ព្រម**

ទី៣. ជ្រើសរើសពាក្យ "New Message"

(ទូរស័ព្ទខ្លះ ចូលដល់ករណីទី៤ តែម្តង)



ទី៤. ជ្រើសរើសពាក្យ "Write Message ឬពាក្យថា Text Message ឬមានទូរស័ព្ទខ្លះមានពាក្យថា Create message" បន្ទាប់មកចុចលើ **សញ្ញាបញ្ជារយល់ព្រម**







ទី៥. សរសេរអក្សរ ដែលអ្នកចង់ផ្ញើ

(សំរាប់កិច្ចការផ្ញើសារសូមមើលឧទាហរណ៍)

**ចំណាំ:** ចំនួនអក្សរអាចសរសេរបាន ១៦០ពាក្យ

## ២.៣.របៀបសរសេរអក្សរ

ការសរសេរអក្សរមានលក្ខណៈ ៣ប្រភេទ ក្នុងការសរសេរ ដូចជាប្រភេទអក្សរអង់គ្លេស អក្សរខ្មែរ និងតំលៃលេខ។ នៅក្នុងការសរសេរអក្សរ មានអក្សរតូច និងអក្សរធំ។ ការសរសេរពាក្យក៏វាមាន ពាក្យភ្ជាប់ជាមួយវចនានុក្រម និងពាក្យដែលមិនភ្ជាប់ជាមួយវចនានុក្រម។

មុននឹងសរសេរអក្សរចូរអ្នកមើល រូបណែនាំដូចខាងក្រោម:




**គ្រាប់ចុចប្តូរអក្សរ** វានឹងមានសញ្ញាដូចខាងក្រោម:

- ចុចលើកទី១ មានសញ្ញា **eZi abc** មានន័យថាសរសេរអក្សរអង់គ្លេស ជាអក្សរតូច ដែលពាក្យនិមួយៗផ្អែកលើវចនានុក្រម។
- ចុចលើកទី២ មានសញ្ញា **eZi ABC** មានន័យថាសរសេរអក្សរអង់គ្លេស ជាអក្សរធំ ដែលពាក្យនិមួយៗផ្អែកលើវចនានុក្រម។
- ចុចលើកទី៣ មានសញ្ញា **abc** មានន័យថាសរសេរអក្សរអង់គ្លេស ជាអក្សរតូច ដែលពាក្យនិមួយៗ មិនផ្អែកលើវចនានុក្រម។
- ចុចលើកទី៤ មានសញ្ញា **ABC** មានន័យថាសរសេរអក្សរអង់គ្លេស ជាអក្សរធំ ដែលពាក្យនិមួយៗ មិនផ្អែកលើវចនានុក្រម។
- ចុចលើកទី៤ មានសញ្ញា **123** មានន័យថាសរសេរជាចំនួនលេខជាភាសាអង់គ្លេស។
- ចុចលើកទី៥ មានសញ្ញា **កខគ** មានន័យថាសរសេរសារជាភាសាខ្មែរ។
- ចុចលើកទី៦ មានសញ្ញា **១២៣** មានន័យថាសរសេរលេខជាភាសាខ្មែរ។

សូមមើលរូបខុសគ្នារវាងអក្សរត្រូវសរសេរ




អេក្រង់នេះ មានន័យថាសរសេរអក្សរធំខាងដើម តួចតួអក្សរបន្ទាប់




អេក្រង់នេះ មានន័យថាសរសេរអក្សរទំរង់តូចៗទាំងអស់




អេក្រង់នេះ មានន័យថាសរសេរជាលេខ

**ចំណាំ:** ពុម្ពអក្សរទាំងអស់នេះ វាមិនមែនមានគ្រប់ចំណុចនោះទេ ទូរស័ព្ទខ្លះមានត្រឹមតែ អក្សរ ABC, abc, 123 តែប៉ុណ្ណោះ។




**ចំណុចត្រូវចងចាំ:** គ្រាប់ចុចនិមួយៗ មានតួអក្សរចំនួន ៣ ឬ ៤តួ និង លេខមួយតួ។ ដូច្នេះដើម្បីចុចវា តួអក្សរណាមួយ ត្រូវចុចឲ្យជាប់តាមចំនួនតួ ឧទាហរណ៍: គ្រាប់បញ្ចូរ លេខ៩ **9 WXYZ** ពេលអ្នកចុចទី១ វាចេញអក្សរ W ចុចទី២ជាប់គ្នាវាចេញអក្សរ X ចុចលើកទី៣ ចេញអក្សរ Y ចុចលើកទី៤ វានិងចេញអក្សរ Z។ សំរាប់លេខវិញ អ្នកត្រូវចុចលើគ្រាប់បញ្ចូរនោះឲ្យជាប់។

# ៣.របៀបសរសេរកូដក្នុងការផ្ញើសារ

## ៣.១. របៀបផ្ញើសារភាពមិនប្រក្រតី (កូដសកម្មភាពលេខ២)

ឧទាហរណ៍: នៅក្នុងភូមិ ទោសបាក់ ឃុំឡាបាន ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅខាងមុខការិយាល័យ ០០១៣ មានកើតភាពមិនប្រក្រតី នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១២ ដូចមានក្នុងទំរង់អង្កេតដូចខាងក្រោម:



គណៈកម្មាធិការដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ខ.៧

(ផ្ទះ១៣៨ ផ្លូវ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ (ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ០២៣ ៨៨៣ ៧៥០ comfrel@online.com.kh)

**ទម្រង់សង្កេតថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៣**

ឈ្មោះអ្នកសង្កេតការណ៍: [illegible] លេខការិយាល័យបោះ/រាប់: 0 0 1 3 ទីតាំងសង្កេតការណ៍

ភូមិ: [illegible] ឃុំ/សង្កាត់: [illegible] ក្រុង/ស្រុក/ខណ្ឌ: [illegible] រាជធានី

/ខេត្ត: [illegible] ថ្ងៃខែឆ្នាំបំពេញទម្រង់: 16./5./២០១២ ហត្ថលេខាអ្នកសង្កេតការណ៍:..............

ហត្ថលេខាអ្នកទំនាក់ទំនងស្រុក:..............

**ចំណាំ៖** សូមប្រើសញ្ញា ✓នេះ នៅក្នុងប្រអប់ទំនេរ ☐នេះ គឺ ដូច ☑នេះ ដើម្បីបញ្ជាក់ថា មានបញ្ហា ឬមានភាពមិនប្រក្រតី ហើយសូមសរសេររៀបរាប់បញ្ជាក់ឲ្យបានក្បោះក្បាយនៅបន្ទាត់ទំនេរខាងក្រោមសំណួរ។

**I.មុនថ្ងៃបោះឆ្នោត១ថ្ងៃ (គឺ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១២)**

| ល.រ/កូដ | សំណួរ ៦ (សកម្មភាពឃោសនា និង សន្តិសុខ) | មានបញ្ហា | ចំនួនករណី | សរុបបណ្តឹង | សរុបបណ្តឹងមិនបានដោះស្រាយ |
|---|---|---|---|---|---|
| ១ | តើមានសកម្មភាពឃោសនាបោះឆ្នោតនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១២ ដែរឬទេ? | ☑ | 10 | 3 | 1 |
| ២ | តើមានបញ្ហាអសន្តិសុខនៅក្នុងភូមិជុំវិញការិយាល័យ ដូចជាការបំភិតបំភ័យ ការគម្រាមកំហែង ភាពចលាចលនានា...ដែរឬទេ? | ☑ | 5 | 5 | 3 |
| ៣ | តើមានបញ្ហាខ្វះសម្ភារៈមួយចំនួនបង្កឲ្យមានការរាំងស្ទះដល់ការបើកការិយាល័យដែរឬទេ? | ☑ | 4 | 2 | 1 |

បើមាន សូមបញ្ជាក់ឲ្យបានច្បាស់លាស់: នៅឯណា? ពេលណា? អ្នកណា ឬគណបក្សណាជាអ្នកប្រព្រឹត្តិ? ជនរងគ្រោះជាអ្នកណា? មានសកម្មភាពយ៉ាងដូចម្តេច? ..............

**ករណីទី១ រូបមន្តសរសេរផ្ញើសារតែមួយសំណួរម្តង**

ដូច្នេះរបៀបសរសេរអក្សរចូលក្នុងទូរស័ព្ទ

ត្រូវអនុវត្តតាមរូបមន្តដូចបង្ហាញខាងក្រោម:

គំរូក្នុងការសរសេរ គឺ 02.220013.1.1x.1y.10.3.1




មានន័យថា:

| *លេខកូដសកម្មភាព.* | *កូដការិយាល័យ.* | *កូដសំណួរ.* | *កូដគណបក្សប្តឹង.* | *កូដគណបក្សត្រូវបានគេប្តឹង.* | *ចំនួនករណី.* | *សរុបបណ្តឹង.* | *សរុបបណ្តឹងមិនបានដោះស្រាយ* |
|---|---|---|---|---|---|---|---|
| 02. | 220013. | 1. | 1x. | 1y. | 10. | 3. | 1 |

**ករណីទី២ រូបមន្តសរសេរផ្ញើសារច្រើនជាងមួយសំណួរ**

យោងតាមទំរង់ខាងលើ គំរូក្នុងការសរសេរ គឺ

02.220013.1.1x.1y.10.3.1,2.1x.1y.5.5.3,3.1x.1y.4.2.1



| លេខកូដ សកម្មភាព. | កូដ ការិយាល័យ. | កូដសំណួរ. | កូដ គណបក្សប្តឹង. | កូដគណបក្ស ត្រូវបានគេប្តឹង. | ចំនួនករណី. | សរុបបណ្តឹង. | សរុបបណ្តឹង មិនបានដោះស្រាយ | កូដសំណួរ. | កូដ គណបក្សប្តឹង. | កូដគណបក្ស ត្រូវបាន គេប្តឹង. | ចំនួនករណី. | សរុបបណ្តឹង. | សរុបបណ្តឹង មិនបាន ដោះស្រាយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 02. | 220013. | 1. | 1x. | 1y. | 10. | 3. | 1, | 2. | 1x. | 1y. | 5. | 5. | 3; |

## ៣.២. របៀបផ្ញើសារលទ្ធផលឆ្នោត (កូដសកម្មភាពលេខ១)

ឧទាហរណ៍: នៅក្នុងភូមិ ទោសបាក់ ឃុំឡាបាន ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅខាងមុខការិយាល័យ ០០១៣ លទ្ធផលឆ្នោតបានពីការរាប់សន្លឹកឆ្នោត។



X. លទ្ធផលសំឡេងឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ

| ល.រ /កូដ | ឈ្មោះគណបក្សនយោបាយ | សំលេងឆ្នោតដែលទទួលបាន (ជាលេខ និងជាអក្សរ) |
|---|---|---|
| ១ | គណបក្ស ប្រជាជនកម្ពុជា | ជាលេខចំនួន 35 |
| ២ | គណបក្ស សម រង្ស៊ី | ជាលេខចំនួន 35 |
| ៣ | គណបក្ស ហ៊្វុនស៊ិនប៉ិច | ជាលេខចំនួន 34 |
| ៤ | គណបក្ស សិទ្ធិមនុស្ស | ជាលេខចំនួន 36 |
| ៥ | គណបក្ស នរោត្តមរណឫទ្ធិ | ជាលេខចំនួន 35 |
| ៦ | គណបក្ស សង្គ្រាមកម្ពុជា | ជាលេខចំនួន 0 |
| ៧ | គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ជាលេខចំនួន 0 |
| ៨ | គណបក្សខ្មែរឈប់ក្រ | ជាលេខចំនួន 0 |
| ៩ | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ | ជាលេខចំនួន 0 |
| ១០ | គណបក្សចលនាប្រជាធិបតេយ្យ | ជាលេខចំនួន 0 |
| | សន្លឹកឆ្នោតបានការសរុប | ជាលេខចំនួន 165 |
| | សន្លឹកឆ្នោតមិនបានការសរុប | ជាលេខចំនួន 0 |
| | សន្លឹកឆ្នោតក្នុងហិបឆ្នោតសរុប | ជាលេខចំនួន 165 |

**ដូច្នេះរូបមន្តក្នុងការសរសេរ** ដោយយោងតាមទំរង់ខាងលើ គំរូក្នុងការសរសេរ គឺ

01.220013.1.35,2.35,3.34,4.36,5.35

**មានន័យថា**




| លេខកូដ សកម្មភាព. | កូដ ការិយាល័យ. | កូដ គណបក្ស | សំលេងឆ្នោត | កូដ គណបក្ស | សំលេងឆ្នោត | កូដ គណបក្ស | សំលេងឆ្នោត | កូដ គណបក្ស | សំលេងឆ្នោត | កូដ គណបក្ស | សំលេងឆ្នោត |
|---|---|---|---|---|---|---|---|---|---|---|---|
| 01. | 220013. | 1. | 35, | 2. | 35, | 3. | 34, | 4. | 36, | 5. | 35 |

## ៤-ការផ្ញើសារមកស្នាក់ការកណ្តាល

សំរាប់ការផ្ញើសារ មកស្នាក់ការកណ្តាល សូម លោក លោកស្រី បញ្ជូនមកលេខ ទូរស័ព្ទ ០៩៧ ៤៤៩ ៧៩១៥។ ពេលសរសេរលេខរួច លោកអ្នកអាចបញ្ជូនតាមទូរស័ព្ទបានហើយ។

**ដំណាក់កាលសរសេរផ្ញើសារ**

ដំណាក់កាលទី១
សរសេរព័ត៌មាននៅលើអេក្រង់ទូរស័ព្ទ
ឲ្យចប់រួចរាល់




ដំណាក់កាលទី២
ចុចលើពាក្យ **បញ្ជារមឺនុយ**
បន្ទាប់មក ជ្រើសរើសពាក្យ Send ចុចលើពាក្យ
**បញ្ជារមឺនុយ** ម្តងទៀត




ដំណាក់កាលទី3 បញ្ចូលលេខទូរស័ព្ទ ដែលត្រូវផ្ញើ
បន្ទាប់មកចុចលើ
គ្រាប់បញ្ជារយល់ព្រម "OK"




**ចំណាំៈ** សំរាប់កម្មវិធីផ្ញើសារនេះ លោក លោកស្រី អាចផ្ញើបានលុះត្រាតែ លេខទូរស័ព្ទអនុញ្ញាតពីស្នាក់ការកណ្តាល របស់ខុមហ្វ្រែល តែបើមិនមានទេសូមបញ្ជូនលេខនោះមកស្នាក់ការកណ្តាល ដើម្បីមានសិទ្ធិបញ្ជូនសារចូលកម្មវិធី បើមិនដូច្នោះទេ សារនោះទុកជាអាសារបង់។

លេខកូដខេត្ត និងលេខកូដផ្សេងទៀត ដែលអ្នកសង្កេតការណ៍ត្រូវធ្វើការចងចាំ

| ល.រ | ឈ្មោះខេត្ត | លេខកូដ |
|---|---|---|
| ១ | បន្ទាយមានជ័យ | 1 |
| ២ | បាត់ដំបង | 2 |
| ៣ | កំពង់ចាម | 3 |
| ៤ | កំពង់ឆ្នាំង | 4 |
| ៥ | កំពង់ស្ពឺ | 5 |
| ៦ | កំពង់ធំ | 6 |
| ៧ | កំពត | 7 |
| ៨ | កណ្តាល | 8 |
| ៩ | កោះកុង | 9 |
| ១០ | ក្រចេះ | 10 |
| ១១ | មណ្ឌលគីរី | 11 |
| ១២ | ភ្នំពេញ | 12 |
| ១៣ | ព្រះវិហារ | 13 |
| ១៤ | ព្រៃវែង | 14 |
| ១៥ | ពោធិសាត់ | 15 |
| ១៦ | រតនគីរី | 16 |
| ១៧ | សៀមរាប | 17 |
| ១៨ | ក្រុងព្រះសីហនុ | 18 |
| ១៩ | ស្ទឹងត្រែង | 19 |
| ២០ | ស្វាយរៀង | 20 |
| ២១ | តាកែវ | 21 |
| ២២ | ឧត្តរមានជ័យ | 22 |
| ២៣ | កែប | 23 |
| ២៤ | ប៉ៃលិន | 24 |

| ល.រ | ឈ្មោះខេត្ត | លេខកូដ |
|---|---|---|
| ២៥ | មិនដឹង | 25 |
| ២៦ | គណៈកម្មការការិយាល័យបោះឆ្នោត | 26 |
| ២៧ | គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត | 27 |
| ២៨ | ផ្សេងៗ | 28 |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

**ចំណាំ**

- លេខកូដដែលអ្នកសរសេរនៅក្នុងអេក្រង់ទូរស័ព្ទ សូមអ្នកកុំភ្លេចបញ្ចូលលេខកូដខេត្ត ២២០០១៣ (មានន័យថា ២២ជាកូដខេត្ត រីឯ ០០១៣ ជាលេខកូដការិយាល័យដែលអ្នកសង្កេត)